ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥

# របាយការណ៍ដើម្បីឆ្លងប្រជុំពេញអង្គរដ្ឋសភានូវ
# សេចក្ដីព្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

**ដោយសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

-សូមគោរពសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

-សូមគោរពឯកឧត្តមអនុប្រធានទី២ នៃរដ្ឋសភា ជាទីគោរព!

-សូមគោរព សម្ដេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ដ៏ឧត្តុង្គឧត្តមនៃរដ្ឋសភា។

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដែលបានសម្រេចដាក់បញ្ចូលនូវសេចក្ដីព្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរបៀបវារៈសម្រាប់សម័យប្រជុំពេញអង្គនៃរដ្ឋសភានាថ្ងៃនេះ។ ព្រមជាមួយនេះ ខ្ញុំក៏សូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការជំនាញនៃរដ្ឋសភា រួមមានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌ ដែលបានពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់លើសេចក្ដីព្រាងច្បាប់នេះ រួមទាំងការរៀបចំនូវសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានាទាំងមជ្ឈដ្ឋានជាតិ និងអន្តរជាតិចំនួន ៥៤០រូប។ ផ្អែកលើអនុសាសន៍ដែលទទួលបានពីអង្គសិក្ខាសាលាពិគ្រោះយោបល់នេះ គណៈកម្មការជំនាញនៃរដ្ឋសភាបានស្នើឲ្យរាជរដ្ឋាភិបាលធ្វើការកែសម្រួលឡើងវិញនូវខ្លឹមសារសំខាន់ៗមួយចំនួន ហើយរាជរដ្ឋាភិបាលបានឯកភាពធ្វើការកែសម្រួលដូចសេចក្ដីព្រាងច្បាប់ ដែលបានដាក់ជូនសម័យប្រជុំពេញអង្គនៃរដ្ឋសភានាឱកាសនេះ។

មុននឹងអង្គសភាទាំងមូលធ្វើការពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ខ្ញុំសូមគោរពអនុញ្ញាតធ្វើសេចក្ដីរាយការណ៍អំពីគោលការណ៍ជាមូលដ្ឋានក្នុងការរៀបចំសេចក្ដីព្រាងច្បាប់ ដំណើរការតាក់តែងសេចក្ដីព្រាងច្បាប់ ខ្លឹមសារសំខាន់ៗ និង

អត្ថប្រយោជន៍ដែលសង្គមជាតិយើងទទួលបាន ក្រោយពីសេចក្តីព្រាងច្បាប់នេះទទួលបានការអនុម័តយល់ព្រមពីរដ្ឋសភា ដូចខាងក្រោម ៖

សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានរៀបចំ និងតាក់តែងដោយផ្អែកលើមូលដ្ឋានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា៤២ កថាខណ្ឌទី១ ដែលបានចែងថា " ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះ ត្រូវបានកំណត់ក្នុងច្បាប់ "។ ទន្ទឹមនេះ សេចក្តីព្រាងច្បាប់នេះ ក៏បានតាក់តែងឡើងលើមូលដ្ឋានច្បាប់នានាជាធរមាននៅកម្ពុជា និងលើមូលដ្ឋាននៃមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមាត្រា ១៥ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ផ្អែកលើគោលការណ៍ខាងលើនេះ ដើម្បីជានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនីតិរដ្ឋ នាពាក់កណ្តាលឆ្នាំ១៩៩៥ ក្រសួងមហាផ្ទៃបានផ្តួចផ្តើមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័ននានា និងមានការគាំទ្របច្ចេកទេសពីអ្នកជំនាញការច្បាប់ អង្គការអន្តរជាតិ និងអ្នកជំនាញការបរទេសមួយចំនួន រួចហើយបានយកសេចក្តីព្រាងច្បាប់នេះទៅពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។

ក្នុងការពិគ្រោះយោបល់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានគាំទ្រក្នុងការរៀបចំឲ្យមានច្បាប់នេះ និងមួយចំនួនទៀតបានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលឲ្យពន្យារការរៀបចំសេចក្តីព្រាងច្បាប់នេះមួយរយៈពេលសិន។ រាជរដ្ឋាភិបាល បានគោរពតាមអនុសាសន៍របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលស្នើសុំពន្យារការអនុម័តច្បាប់នេះ។ ក្នុងរយៈពេលនៃការពន្យារពេលអនុម័តច្បាប់នេះ រាជរដ្ឋាភិបាលបានខិតខំធ្វើការប្រមែប្រមូលនូវអនុសាសន៍ពីអ្នកពាក់ព័ន្ធនានា និងខិតខំធ្វើការសិក្សាស្រាវជ្រាវបទពិសោធន៍ពីប្រទេសនានាក្នុងតំបន់ និងលើសកលលោក ជាបន្តបន្ទាប់រហូតមកទល់ដើមឆ្នាំ២០១១ ទើបរាជរដ្ឋាភិបាលបានលើកយកសេចក្តីព្រាងច្បាប់នេះ មកធ្វើការពិនិត្យកែសម្រួលឡើងវិញ និងបានរៀបចំឲ្យមានសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ដោយមានតំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធនានាប្រមាណ ២៧០រូប។ ផ្អែកលើអនុសាសន៍ដែលប្រមូលបានពីសិក្ខាសាលានេះ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្រុមការងារតាក់តែងច្បាប់របស់រាជរដ្ឋាភិបាល បានជួបពិភាក្សាដោយឡែកៗជាមួយតំណាងស្ថានទូតនានាប្រចាំកម្ពុជា អង្គការអន្តរជាតិ សមាគម អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗមួយចំនួន ដើម្បីប្រមែប្រមូលអនុសាសន៍ជាបន្ថែមទៀត និងបានពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់នេះ ដើម្បី

ដាក់ជូនសិក្ខាសាលាពិគ្រោះយោបល់ជាលើកទី២ នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានាចំនួន ១៥៣រូប។

ផ្អែកតាមសិក្ខាសាលាពិគ្រោះយោបល់ និងការជួបពិភាក្សាដោយឡែកៗ ដូចបានគោរពរាយការណ៍ជូនខាងលើនេះ ជារួម មតិភាគច្រើនបានគាំទ្រឲ្យមានការរៀបចំច្បាប់នេះ ជាមួយការផ្តល់អនុសាសន៍ ដើម្បីពិនិត្យកែលម្អសេចក្តីព្រាងច្បាប់។ ទន្ទឹមនេះ ក៏មានមតិមួយចំនួនបានផ្តល់អនុសាសន៍ស្នើឲ្យពន្យារការអនុម័តសេចក្តីព្រាងច្បាប់នេះមួយរយៈពេលជាបន្តទៀត។ ផ្អែកលើសំណូមពរនេះ រាជរដ្ឋាភិបាលក៏បានបន្តពន្យារពេលការអនុម័តលើសេចក្តីព្រាងច្បាប់តាមយោបល់របស់សមាគម អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ក្នុងរយៈពេលនៃការពន្យារនេះ ក្រុមការងាររាជរដ្ឋាភិបាល ក៏បានបន្តប្រមូលអនុសាសន៍នានាដែលទទួលបានកន្លងមក ហើយធ្វើការសំយោគនូវអនុសាសន៍ដែលមានលក្ខណៈស្របគ្នា និងអនុសាសន៍ ដែលមានលក្ខណៈមិនស្របគ្នា រួមទាំងការបន្តសិក្សាស្វែងយល់បន្ថែមលើបទពិសោធន៍ជាអន្តរជាតិ ដើម្បីពិនិត្យកែលម្អសេចក្តីព្រាងច្បាប់នេះ ដាក់ជូនសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥។ បន្ទាប់ពីទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី សេចក្តីព្រាងច្បាប់នេះត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមករដ្ឋសភា ហើយគណៈកម្មការជំនាញនៃរដ្ឋសភាក៏បានសហការជាមួយតំណាងរាជរដ្ឋាភិបាល រៀបចំឲ្យមានសិក្ខាសាលាពិគ្រោះយោបល់ កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ដោយមានអ្នកពាក់ព័ន្ធនានាចូលរួមចំនួន ៥៤០ រូប។ ផ្អែកលើអនុសាសន៍ដែលប្រមូលបានពីសិក្ខាសាលាពិគ្រោះយោបល់នេះ គណៈកម្មការជំនាញទាំងបីនៃរដ្ឋសភា និងតំណាងរាជរដ្ឋាភិបាល បានខិតខំសំយោគនូវអនុសាសន៍ដែលមានលក្ខណៈស្របគ្នា និងមានហេតុផលសមស្របច្បាស់លាស់ ដើម្បីធ្វើការកែលម្អនូវសេចក្តីព្រាងច្បាប់ ដូចដែលបានដាក់ជូនសម័យប្រជុំពេញអង្គនៃរដ្ឋសភានាពេលនេះ។ សេចក្តីព្រាងច្បាប់នេះ មានចំនួន ៩ជំពូក និងចែកចេញជា ៣៩ មាត្រា។

សរុបមក សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាននៅកម្ពុជា ព្រមទាំងលិខិតតូបករណ៍អន្តរជាតិដែលកម្ពុជាយើងបានទទួលស្គាល់ ជាមួយដំណើរការរៀបចំដែលមានការចូលរួមការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ជាច្រើនដំណាក់កាល ស្របតាមគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យក្នុងរយៈពេលប្រមាណ ២០ឆ្នាំ បើគិតចាប់តាំងពីឆ្នាំ១៩៩៥មក។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏សមាគមអង្គការមិនមែនរដ្ឋាភិបាល និងមជ្ឈដ្ឋានខ្លះនៅតែមានកង្វល់ និងការព្រួយបារម្ភមួយចំនួនមកលើសេចក្តីព្រាងច្បាប់នេះ ដោយស្នើឲ្យពន្យារពេលអនុម័តច្បាប់នេះ ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិគ្រោះពិភាក្សាលើសេចក្តីព្រាងច្បាប់ និងមជ្ឈដ្ឋានខ្លះបានលើកឡើងថា កម្ពុជាពុំចាំបាច់មានច្បាប់នេះឡើយ។ អនុសាសន៍ និងយោបល់ទាំងនេះ ជាអនុសាសន៍ និងយោបល់ដែល

មិនមានហេតុផលសមស្រប និងឆ្លុះបញ្ចាំងនូវបំណងពិតប្រាកដឡើយ។ អាស្រ័យហេតុនេះ ខ្ញុំសូមគោរពអនុញ្ញាតពីអង្គប្រជុំរដ្ឋសភា ធ្វើការគូសបញ្ជាក់នូវខ្លឹមសារសំខាន់ៗនៃសេចក្ដីព្រាងច្បាប់នេះដូចខាងក្រោម ៖

១-ច្បាប់នេះមានគោលបំណងធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជាលើគ្រប់វិស័យ។ មកទល់បច្ចុប្បន្ន មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ប្រមាណ ៥០០០ (ប្រាំពាន់) ដែលបានតម្កល់ឯកសារសំណុំលិខិតសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ក្នុងលក្ខណៈជាបណ្ដោះអាសន្ន និងមិនទាន់មានបុគ្គលិកលក្ខណៈសម្បត្តិជានីតិបុគ្គលស្របតាមគោលការណ៍ច្បាប់នៅឡើយ។ ផ្អែកតាមបទប្បញ្ញត្តិ នៃមាត្រា៣៧ និងមាត្រា៣៨ នៃសេចក្ដីព្រាងច្បាប់នេះ បានចែងថា " បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជី និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គល ស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះ"។ ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជីស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ ហើយអាចដាក់ពាក្យសុំបន្តសុពលភាពអនុស្សរណៈសម្រាប់រយៈពេល៣ឆ្នាំទៀត ឲ្យបាន៩០ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ។

ផ្អែកតាមបទប្បញ្ញត្តិខាងលើនេះ ច្បាប់នេះមិនមានប្រតិសកម្មជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ប្រមាណ ៥០០០(ប្រាំពាន់) ដែលបានតម្កល់ឯកសារនៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឡើយ។ មានន័យថា សមាគម និងអង្គការទាំងនោះ បន្តធ្វើសកម្មភាពដោយមានការការពារយ៉ាងពេញលេញក្រោមច្បាប់នេះ និងច្បាប់នានាជាធរមាននៅកម្ពុជា។ មាត្រា៣៥ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា " ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"។ ដូច្នេះ សេចក្ដីព្រាងច្បាប់នេះ មិនមានគោលបំណងណាមួយក្នុងការគាបសង្កត់ កម្រិតសិទ្ធិសេរីភាពបុគ្គលក្នុងការបញ្ចេញមតិ និងក្នុងការចូលរួមជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចដែលមជ្ឈដ្ឋានខ្លះបានលើកឡើងនោះឡើយ។ មានន័យថា ប្រជាពលរដ្ឋម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងចូលរួមក្នុង

ជីវភាពនយោបាយ ទោះបីបុគ្គលនោះជាមេដឹកនាំ ឬជាសមាជិកនៃអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ។ ប៉ុន្តែការធ្វើសកម្មភាពក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងន័យគាំទ្រ ឬប្រឆាំងទៅនឹងគណបក្សនយោបាយណាមួយ ត្រូវបានហាមឃាត់ដោយច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

២-អំពីលក្ខខណ្ឌ សំណុំឯកសារ បែបបទ នីតិវិធីនៃការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដូចមានចែងក្នុងជំពូកទី២ នៃសេចក្តីព្រាងច្បាប់នេះ ត្រូវបានដកស្រង់យកបទពិសោធន៍ពីកិច្ចដំណើរការ នៃការតម្កល់សំណុំឯកសារសម្រាប់ការបង្កើត និងការចុះបញ្ជីក្នុងលក្ខណៈជាបណ្តោះអាសន្នរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្រសួងមហាផ្ទៃកន្លងមក សម្រាប់ជាមូលដ្ឋានតាក់តែងនូវបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសំណុំឯកសារ រួមទាំងជីវប្រវត្តិស្ថាបនិក និងការរៀបចំលក្ខន្តិកៈសម្រាប់ធ្វើជាបែបបទ និងនីតិវិធីក្នុងការបង្កើត និងការចុះបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល សំដៅជានាដល់ការរីកចម្រើននៃសង្គមស៊ីវិលនៅកម្ពុជា ដែលជានាការពារយ៉ាងពេញលេញដោយច្បាប់នេះ។ ក្នុងដំណើរការបង្កើត និងចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់បានកំណត់ពេលវេលាជាក់លាក់ក្នុងការទទួលការឆ្លើយតប ឬការកែតម្រូវណាមួយ ដែលក្រសួងមហាផ្ទៃត្រូវគោរពឲ្យបានត្រឹមត្រូវនូវរយៈពេលដែលបានកំណត់នេះ។ ក្នុងករណីដែលក្រសួងមហាផ្ទៃមិនបានឆ្លើយតបតាមរយៈពេលដែលកំណត់ដោយច្បាប់ទេនោះ ត្រូវចាត់ទុកថាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះ បានចុះបញ្ជីជាស្វ័យប្រវត្តិ។ បទប្បញ្ញត្តិនេះ មានគោលបំណងបង្ការទប់ស្កាត់ការិយាធិបតេយ្យក្នុងការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ទន្ទឹមនេះ សេចក្តីព្រាងច្បាប់បានចែងថា " សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលក្រសួងមហាផ្ទៃសម្រេចបដិសេធចំពោះការស្នើសុំចុះបញ្ជី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិប្តឹងទៅតុលាការ "។

ដូច្នេះ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនមានលក្ខណៈសាំញ៉ាំ ការិយាធិបតេយ្យ ដូចការព្រួយបារម្ភរបស់មជ្ឈដ្ឋានខ្លះដែលបានលើកឡើងនោះឡើយ។ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ គឺអនុលោមតាមគោលការណ៍បែងចែកអំណាច រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ សំដៅជានាការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ស្របតាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៣-ចំពោះការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដូចមានចែងក្នុងជំពូកទី៣នៃសេចក្តីព្រាងច្បាប់នេះ គឺសំដៅលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបង្កើតក្រោមច្បាប់បរទេស ហើយមានបំណងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា

តម្រូវឲ្យចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់នៃការចុះអនុស្សរណៈដូចដែលបាន និងកំពុងអនុវត្តនាពេលបច្ចុប្បន្ន។ ទន្ទឹមនេះ សេចក្តីព្រាងច្បាប់នេះបានបន្ធូរបន្ថយលក្ខខណ្ឌមួយដែលមានចែងក្នុងអនុស្សរណៈបច្ចុប្បន្ន ដែលកំណត់អំពីថវិកាសម្រាប់ចំណាយក្នុងបុព្វហេតុរដ្ឋបាល រួមមានបៀវត្សរ៍របស់បុគ្គលិក សម្ភារការិយាល័យ និងការចំណាយសម្រាប់ដំណើរការការងារក្នុងការិយាល័យ មិនឲ្យលើសពី ២៥%(ម្ភៃប្រាំភាគរយ) សំដៅសម្រួលដល់កិច្ចដំណើរការរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសនៅព្រះរាជាណាចក្រកម្ពុជា។

ដូច្នេះ បែបបទចុះបញ្ជីក្រោមទម្រង់នៃការចុះអនុស្សរណៈសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានបំណងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា មិនមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញនោះឡើយ។ លើសពីនេះ ក្រោមច្បាប់នេះកម្ពុជាបានអនុញ្ញាតឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា ផ្ទុយពីច្បាប់ប្រទេសខ្លះដែលបានរឹតត្បិត ឬបានហាមឃាត់។

៤-សេចក្តីព្រាងច្បាប់ បានតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលធ្វើជូនក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ហើយក្នុងករណីអង្គការមិនមែនរដ្ឋាភិបាលណាមួយ ទទួលមូលនិធិពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលនោះគ្រាន់តែចម្លងចេញពីឯកសារដើម ដែលបានស្នើទៅម្ចាស់ជំនួយ និងចម្លងចេញពីឯកសារដើមនូវគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដែលម្ចាស់ជំនួយបានយល់ព្រម សម្រាប់ជារបាយការណ៍ប្រចាំឆ្នាំ តែប៉ុណ្ណោះ។ ចំពោះសមាគមក្នុងស្រុក សេចក្តីព្រាងច្បាប់នេះតម្រូវឲ្យធ្វើតែរបាយការណ៍ខាងលើនេះ តែក្នុងករណីចាំបាច់តាមការស្នើសុំពីក្រសួងមហាផ្ទៃតែប៉ុណ្ណោះ។

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាប្រភេទអង្គការមិនស្វែងរកប្រាក់ចំណេញ ឬប្រាក់កម្រៃមកចែកគ្នា ហេតុនេះតាមបទពិសោធន៍ជាអន្តរជាតិ អង្គការមិនស្វែងរកប្រាក់កម្រៃតែងតែតម្រូវឲ្យធ្វើរបាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលជាទៀតទាត់ សំដៅលើកកម្ពស់តម្លាភាព គណនេយ្យភាពក្នុងសង្គម ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ចំណុចពិសេសនៃសេចក្តីព្រាងច្បាប់នេះ គឺកម្ពុជាបានអនុញ្ញាតឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទទួលបានហិរញ្ញប្បទានពីបរទេស ផ្ទុយពីប្រទេសខ្លះដែលហាមឃាត់មិនឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទទួលហិរញ្ញប្បទានពីបរទេស ឬអាចទទួលបានលុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋាភិបាល។

៥-ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមបញ្ជាក់ជូនអង្គសភាទាំងមូលមេត្តាជ្រាបថា សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនមានគោលបំណង និងគោលដៅណាមួយរឹតត្បិតសិទ្ធិសេរីភាពក្នុងការបង្កើត និងការធ្វើសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដូចដែលមជ្ឈដ្ឋានខ្លះមានការព្រួយបារម្ភនោះឡើយ។ ក្នុងសង្គមប្រជាធិបតេយ្យ សិទ្ធសេរីភាព និងនីតិរដ្ឋ គឺជាកិច្ចដំណើរការដែលមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា " ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ "។ ដូច្នេះ សេចក្តីព្រាងច្បាប់នេះមានគោលបំណង និងគោលដៅការពារ និងលើកកម្ពស់សិទ្ធសេរីភាពប្រជាពលរដ្ឋគ្រប់រូបក្នុងសង្គម ស្របតាមគោលការណ៍នីតិរដ្ឋ សំដៅជានាដល់ការអភិវឌ្ឍសង្គមជាតិប្រកបដោយចិរភាព ស្របតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា។

៦-ផ្អែកតាមគោលបំណង គោលដៅ និងខ្លឹមសារសំខាន់ៗ ដូចដែលបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលសង្ឃឹមថា សេចក្តីព្រាងច្បាប់នេះនឹងផ្តល់អត្ថប្រយោជន៍ដល់សង្គមកម្ពុជាទាំងមូល ដែលក្នុងនោះ រួមានជាអាទិ៍៖

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលតម្កល់ឯកសារសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវបានចាត់ទុកជាការចុះបញ្ជីដោយស្របច្បាប់ និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គល ដែលច្បាប់ការពារមិនឲ្យមានការរំលោកបំពានណាមួយឡើយ។ ចំពោះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានចាត់ទុកថាបានចុះបញ្ជី និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ

- បង្កលក្ខណៈសម្បត្តិងាយស្រួលដល់ការកកើតឡើងនូវសមាគម និងអង្គការមិនមែនរដ្ឋាភិបាលថ្មីៗបន្ថែមទៀត ដើម្បីបន្តចូលរួមចំណែកអភិវឌ្ឍសង្គមកម្ពុជាលើគ្រប់វិស័យ

- ច្បាប់បានដាក់កាតព្វកិច្ចដល់ស្ថាប័នសាធារណៈទាំងអស់ ត្រូវតែលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពស្របច្បាប់ និងស្របតាមលក្ខន្តិកៈរបស់ខ្លួន ដោយគ្មានស្ថាប័ន អង្គការ ឬបុគ្គលណាមួយមករំលោភបំពានបានឡើយ

ទន្ទឹមនេះ សេចក្តីព្រាងច្បាប់នេះមិនមានវិសាលភាពគ្របដណ្តប់ទៅលើអង្គការ សហគមន៍តូចៗនៅមូលដ្ឋាន ដែលមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមមាត្រា៦ និងមាត្រា៧ នៃសេចក្តីព្រាងច្បាប់នេះ ហើយដែលប្រជាពលរដ្ឋរួមគ្នាបង្កើតឡើងក្នុងគោលបំណងសហការជួយគ្នាទៅវិញទៅមក ឬដើម្បីការពារផលប្រយោជន៍របស់បងប្អូន និងផលប្រយោជន៍របស់សហគមន៍នានានៅតាមមូលដ្ឋាននោះឡើយ។ អាស្រ័យហេតុនេះ សូមអង្គការ សហគមន៍ និងប្រជាពលរដ្ឋទាំងអស់ បន្តធ្វើសកម្មភាពអភិវឌ្ឍសហគមន៍របស់បងប្អូនប្រកបដោយភាពសុខដុមរមនា ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិរបស់យើងជាបន្តទៀត។

ស្របជាមួយគ្នានេះ បន្ទាប់ពីរដ្ឋសភាពិនិត្យ និងអនុម័ត ហើយច្បាប់នេះបានចូលជាធរមាន រាជរដ្ឋាភិបាលនឹងបន្តសហការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាដោយអនុវត្តច្បាប់នេះ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីធានាការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ក្នុងការអនុវត្ត ករណីមានការប៉ះពាល់ដល់សិទ្ធិសេរីភាព និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ឬសកម្មភាពស្របច្បាប់របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា រដ្ឋសភាដែលជាតំណាងឲ្យសម្លេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យការអនុវត្តច្បាប់នេះ និងមានសិទ្ធិគ្រប់គ្រាន់ ដើម្បីស្នើធ្វើវិសោធនកម្មច្បាប់នេះ ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋកម្ពុជា។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ សូមអង្គសភាទាំងមូលមេត្តាពិនិត្យ និងអនុម័ត នូវសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយសេចក្តីអនុគ្រោះបំផុត។

**សូមអរគុណ!**